ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber

Chambre de la Cour suprême

សំណុំរឿងលេខ: ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/អ.ជ.ដ/អ.ជ.ត.ក

Case File/Dossier N°. 004/2/07-09-2009-ECCC/TC/SC

**នៅចំពោះមុខ៖**
**ចៅក្រម គង់ ស្រីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម ម៉ុង មុន្នីចរិយា**
**ចៅក្រម Maureen Harding CLARK**
**ចៅក្រម យ៉ា ណារិន**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 17-Jun-2020, 12:10
CMS/CFO: Sann Rada

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០២០
**ភាសាដើម៖** ខ្មែរ/អង់គ្លេស
**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ:

---

# សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំការអនុញ្ញាតចូលធ្វើអន្តរាគមន៍ក្នុងសំណុំរឿង ០០៤/២ ស្តីពីយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល

---

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង

Brenda J. HOLLIS

**<u>ជនជាប់ចោទ</u>**

យឹម ទិត្យ

**<u>សហមេធាវីជនជាប់ចោទ</u>**

សូ មូស្សេនី

Suzana TOMANOVIĆ

សំណុំរឿងលេខៈ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/អ.ជ.ដ/អ.ជ.ត.ក

ឯកសារលេខ E004/2/4/1

**ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២**

**<u>សហមេធាវីជនជាប់ចោទ អោ អាន</u>**

មុំ លុជ្ស
Goran SLUITTER
Richard ROGERS

**អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" ឬ"អ.វ.ត.ក")

**បានទទួល**"សំណើរបស់ យឹម ទិត្យ សុំការអនុញ្ញាតចូលធ្វើអន្តរាគមន៍ក្នុងសំណុំរឿង ០០៤/២ លើយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល"("សំណើសុំការអនុញ្ញាតចូលធ្វើអន្តរាគមន៍")[1] និង"សំណើរបស់ យឹម ទិត្យ សុំដាក់មួយភាសានៃសំណើសុំការអនុញ្ញាតចូលអន្តរាគមន៍ ក្នុងសំណុំរឿង ០០៤/២"("សំណើសុំដាក់មួយភាសា")[2]

**រំឭកថា**"បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង" ("បណ្តឹងសាទុក្ខភ្លាមៗ")[3]

**កត់សម្គាល់**ថា សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា ការដែលអង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការចាត់ការបន្តការជំនុំជម្រះលើសំណុំរឿង ០០៤/២ ប្រឆាំងនឹង អោ អាន នាំឱ្យមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធីសំណុំរឿងនេះ ដូច្នេះជាលទ្ធផល តម្រូវឱ្យសហព្រះរាជអាជ្ញាដាក់បណ្តឹងសាទុក្ខភ្លាមៗ ដោយអនុលោមតាមវិធាន ១០៤(៤)(ក) នៃវិធាផ្ទៃក្នុង

**ហេតុដូច្នេះ** បណ្តឹងសាទុក្ខភ្លាមៗបានជម្រុញផងដែរឱ្យមានការដាក់សំណើក្នុងពេលបច្ចុប្បន្នដោយ យឹម ទិត្យ សុំការអនុញ្ញាតចូលធ្វើអន្តរាគមន៍តាមរយៈការដាក់សារណាស្តីពីយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូលដោយមូលហេតុថា យឹម ទិត្យ មានអត្ថប្រយោជន៍ស្របច្បាប់ក្នុងសំណើបច្ចុប្បន្ន ដើម្បីធានាសមភាព និងជៀសវាងព្យសនកម្មដល់រឿងក្តីរបស់ខ្លួន[4]

---

[1] សំណើរបស់ យឹម ទិត្យ សុំការអនុញ្ញាតធ្វើអន្តរាគមន៍ក្នុងសំណុំរឿង ០០៤/២ លើយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០២០ ឯកសារលេខ E004/2/3។

[2] សំណើរបស់ យឹម ទិត្យ សុំការអនុញ្ញាតដាក់មួយភាសានៃសំណើសុំធ្វើអន្តរាគមន៍ក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០២០ ឯកសារលេខ E004/2/4។

[3] បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងអានុភាពបញ្ចប់សំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០២០ ឯកសារលេខ E004/2/1។

[4] សំណើសុំការអនុញ្ញាតធ្វើអន្តរាគមន៍ កថាខណ្ឌ ១ និង ៧។

**ពិចារណាឃើញថា** ការដាក់ឯកសារពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខភ្លាមៗ ដូចដែលមានចែងក្នុងសេចក្តីណែនាំអនុវត្ត និងក្របខ័ណ្ឌការងារស្តីពីនីតិវិធីរបស់ អ.វ.ត.ក. ត្រូវបានបំពេញ[5] និងថា ដោយសារសំណើរបស់ យឹម ទិត្យ សុំចូលធ្វើអន្តរាគមន៍មានលក្ខណៈជាការរំពឹងរង់ចាំ ដូច្នេះជាការផ្តល់នូវអត្ថប្រយោជន៍ក្នុងការពន្លឿនដំណើរការនីតិវិធី និងសេដ្ឋកិច្ចតុលាការក្នុងការចេញសេចក្តីសម្រេចបច្ចុប្បន្នដោយពុំចាំបាច់រង់ចាំរហូតដល់ផុតពេលកំណត់ឱ្យដាក់សារណាតបនោះឡើយ

**ដោយបានពិចារណាពេញលេញ**លើសំណើរបស់ យឹម ទិត្យ សុំការអនុញ្ញាតធ្វើអន្តរាគមន៍

**យល់ឃើញ**ថា សំណុំរឿងរបស់ យឹម ទិត្យ បច្ចុប្បន្នកំពុងមានអត្ថិភាពនៅចំពោះមុខអង្គបុរេជំនុំជម្រះ និងថា សំណើបច្ចុប្បន្នមានសក្តានុពលធ្វើបុរេវិនិច្ឆ័យលើលទ្ធផលនៃរឿងក្តី[6]

**ដោយបានពិចារណាឃើញ**ថា អនុលោមតាមក្របខ័ណ្ឌផ្នែកច្បាប់ និងយុត្តិសាស្ត្រ និងដោយផ្អែកតាមយុត្តាធិការរបស់ខ្លួន យុត្តាធិការលើបណ្តឹងឧទ្ធរណ៍របស់អង្គបុរេជំនុំជម្រះពុំត្រូវបានរារាំងដោយភាគី *ណាមួយ* ដែលស្នើសុំលើកបញ្ហាមុនពេលកំណត់ ដោយក្នុងពេលតំណាលគ្នាសំអាងទៅលើយុត្តាធិការបណ្តឹងសាទុក្ខរបស់អង្គជំនុំជម្រះតុលាការកំពូល ដោយហេតុផលថា ភាគីមានអត្ថប្រយោជន៍ស្របច្បាប់នោះឡើយ[7]

---

[5] បណ្តឹងសាទុក្ខភ្លាមៗត្រូវបានជូនដំណឹងនៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០២០។ សារណាតបរបស់ អោ អាន ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងអានុភាពបញ្ចប់សំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង បញ្ជូនមកនៅថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០២០ និងជូនដំណឹងនៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០២០ ឯកសារលេខ E004/2/1/1។ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងលិខិតរបស់ អោ អាន ពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងអានុភាពបញ្ចប់សំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០២០ ឯកសារលេខ E004/2/1/1/1។

[6] យឹម ទិត្យ បានលើកឡើងថា "ហេតុដូច្នេះ គេអាចប្រមើលដឹងថា សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងកាលៈទេសៈបែបនេះ នឹងជម្រុញឱ្យមានការអូសបន្លាយកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤។ [..] ថា សេចក្តីសម្រេចណាមួយលើបណ្តឹងសាទុក្ខភ្លាមៗ អាចរួមចំណែកដល់ការធានាថា សហព្រះរាជអាជ្ញាអន្តរជាតិនឹងអនុវត្តវិធីសាស្ត្រខុសពីធម្មតាដដែលនេះទៀតក្នុងសំណុំរឿង ០០៤" កថាខណ្ឌ ៧ សំណើរបស់ យឹម ទិត្យ សុំការអនុញ្ញាតធ្វើអន្តរាគមន៍។

[7] វិធាន ៧៦(៧) នៃវិធានផ្ទៃក្នុងចែងថា "លើកលែងតែជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដីកាដំណោះស្រាយត្រូវកែតម្រូវកំហុសនៃការមិនគោរពវិធាន បញ្ញត្តិក្នុងការស៊ើបសួរ"។ សិទ្ធិអំណាចរបស់អង្គបុរេជំនុំជម្រះ មានសារៈសំខាន់ និងកំណត់ច្បាស់លាស់ថា "គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធទៅនឹងកំហុសនីតិវិធីបែបនេះ អាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលឡើយ"។ ជាផលវិបាក អង្គបុរេជំនុំជម្រះមានតួនាទីទទួលខុសត្រូវធានានៅដំណាក់កាលស៊ើប

**សន្និដ្ឋាន**ថា សំណើរបស់ យឹម ទិត្យ សុំការអនុញ្ញាតចូលអន្តរាគមន៍ អាចជាការជ្រៀតជ្រែកចូលក្នុងយុត្តាធិការរបស់អង្គបុរេជំនុំជម្រះ និងជាការប្រាប់ឱ្យដឹងជាមុនពីលទ្ធផលនៃសំណុំរឿងរបស់ខ្លួន ដែលកំពុងមានអត្ថិភាពនៅមុខអង្គបុរេជំនុំជម្រះ[8]។

**អាស្រ័យហេតុនេះ**

**សម្រេចបដិសេធ** សំណើរបស់ យឹម ទិត្យ សុំការអនុញ្ញាតធ្វើអន្តរាគមន៍

និង**ប្រកាស**ថា សំណើរបស់ យឹម ទិត្យ សុំដាក់មួយភាសា ចាត់ទុកជាអសារបង់។

**រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០២០**

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ីម**

---

អង្កេតថា គោលការណ៍ជាសារវន្តដែលបង្កប់នូវកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌជាធរមាននៅចំពោះមុខ អ.វ.ត.ក. ត្រូវតែគោរព *ការពិចារណារបស់អង្គបុរេជំនុំជម្រះ* ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៩ ឯកសារលេខ D359/24 និង D360/33 កថាខណ្ឌ ៥២។

[8] យឹម ទិត្យ អះអាងថា “ជាការទំនងបំផុត ផ្អែកលើគោលការណ៍នៃសមភាពតទល់ ដែលថា អង្គបុរេជំនុំជម្រះនឹងរក្សាគោលជំហរឯកច្ឆ័នរបស់ខ្លួនទាក់ទងទៅនឹងភាពពុំស្របតាច្បាប់នៃការចេញដីកាដំណោះស្រាយពីរ។ [..] សហព្រះរាជអាជ្ញាអន្តរជាតិកំពុងតែបង្កឱ្យមានការជាប់ផុងនៃសំណុំរឿង ០០៤/២ តាមរយៈការដាក់សារណាដែលពុំអាចទទួលយកបានតាមទម្រង់ទាំងស្រុង ទៅអង្គជំនុំជម្រះសាលាដំបូង ហើយបច្ចុប្បន្នទៅអង្គជំនុំជម្រះតុលាការកំពូល និងព្យាយាមជម្រុញសំណុំរឿងនេះផ្ទុយពីវិធានស្តីពីនីតិវិធីរបស់ អ.វ.ត.ក. [..]” កថាខណ្ឌ ៧ សំណើរបស់ យឹម ទិត្យ សុំការអនុញ្ញាតធ្វើអន្តរាគមន៍។ *សូមមើលផងដែរ* កថាខណ្ឌ ១៣ យឹម ទិត្យ បញ្ជាក់សាជាថ្មីថា “គេអាចប្រមើលដឹងថា ក្នុងព្រឹត្តិការណ៍ដែលសំណុំរឿង ០០៤ បានមកដល់ចំណុចរួមនៃនីតិវិធី សហព្រះរាជអាជ្ញាអន្តរជាតិនឹងត្រូវដាក់ទឡ្ហីករណ៍ប្រហាក់ប្រហែលគ្នានេះទៅអង្គជំនុំជម្រះតុលាការកំពូល”។